អនាគត នៃ ការតស៊ូ

សហគមន៍ អឺរ៉ុប ដកហូត ការអនុគ្រោះ ពន្ធ EBA[1] មួយផ្នែក ពី កម្ពុជា មាន អត្រា ២០% ស្មើនឹង ចំនួន ទឹកប្រាក់ ប្រមាណ ១ ពាន់ លាន ដុល្លារ សហរដ្ឋអាមេរិក[2]។ នៅលើ ពិភពលោក នេះ មាន ៦៥ ប្រទេស ទន់ខ្សោយ ដែល ទទួល បាន ការអនុគ្រោះ ពន្ធ នេះ ដែល ជា វិធានការ សំរាប់ ជួយឧបត្ថម្ភ ការអភិវឌ្ឍន៍ សេដ្ឋកិច្ច នៃ ប្រទេស ទាំងនោះ។ ជាលើក ទី១ មួយហើយ ហើយ ជា ប្រទេស ទី១ ផងដែរ ដែល សមគមន៍ អឺរ៉ុប គេ ធ្វើ ការសំរេ ចចិត្ត ដាក់ទណ្ឌកម្ម ចំពោះការខកខាន មិនបាន គោរព សិទ្ធិ មនុស្ស និង នយោបាយ នៅ កម្ពុជា។ ការដាក់ទណ្ឌកម្ម នេះ មាន លក្ខណៈ ជា ការដាក់ទណ្ឌកម្ម ខាង សីលធម៌ ជាង សេដ្ឋ កិច្ច បើ យោងទៅតាម អត្រា ទាប នៃ ការដកហូត ការ អនុគ្រោះ ពន្ធ។ តែ ខាង សីលធម៌ វា មាន ទំហំ ធំណាស់ ព្រោះ ជា ផ្លូវការ លើក ឆាក អន្តរជាតិ, លើកលែង តែ ប្រទេស មួយ ចំនួន តិចណាស់ ដែល គាំទ្រ របប ដឹកនាំ នៅ កម្ពុជា, គេ ទុក ស្រុកខ្មែរ ជា ប្រទេស ដឹកនាំ ដោយ របប ផ្តាច់ការ។ ជា ការពិត របប នៅភ្នំពេញ មាន អំណរ ព្រោះ មើលឃើញ អត្រា ទាប ដោយ នឹកស្មាន ថា ជា លិខិតអនុញ្ញាត ឱ្យ ខ្លួន បន្ត ធ្វើ សកម្មភាព ភេរវកម្ម ទៅលើ ប្រជាពលរដ្ឋ និង ប្រឆាំងនឹង

[1] EBA : everything but arms (អ្វីគ្រប់យ៉ាង លើកលែង តែ អាវុធ)
[2] ចំនួន ទឹកប្រាក់ ទាំងអស់ មាន ប្រមាណ ៧ ពាន់ លាន ដុល្លារ។

លទ្ធិប្រជាធិបតេយ្យ។ អំណរ នេះ ជា ការពិត មែន បើយោង ទៅតាម អកម្មភាព នៃ ប្រជាពលរដ្ឋ និង នយ:ជន[3]ខ្មែរ ភាគ ច្រើន ជា អ្នកប្រជាធិបតេយ្យ ដោយ នាំគ្នា សម្រាន្ត សង្ឃឹម ចាំ ដំណោះស្រាយ ពី បរទេស សំរាប់ ស្រុកខ្មែរ។ ការរង់ចាំ បែប នេះ ដែល នាំ បង្ហាញ នូវ រូបភាព នៃ ប្រជាពលរដ្ឋខ្មែរ ជា ប្រជា ពលរដ្ឋ ទីពឹងជំនួយ។ ឥរិយាបទ នេះ វា ជា អំណោយផល ដល់ អំណាច ផ្តាច់ការ ព្រោះ ថា ប្រជាពលរដ្ឋ គ្មាន អត្តិភាព ផ្ទាល់ ខ្លួន សំរាប់ កសាង ជោគវាសនា របស់ ខ្លួន ដោយ ខ្លួនឯង។ ដូច្នេះ របប ក្រុងភ្នំពេញ គ្មាន មូលហេតុ នឹងប្តូរ អ្វី ដែល នាំ រំខាន ដល់ អត្តភាព ជាសុក របស់ គេ នោះឡើយ ទោះបី គេ ទទួល សម្ពាធ ពី សហគមន៍ អន្តរជាតិ ក៏ដោយ។ អធិបតេយ្យ ភាព ដែល របប ក្រុងភ្នំពេញ គេ យក មក ធ្វើ ជា ខែល ការពារ នៅ ចំពោះមុខ ការរិះគន់ ពី សំណាក់ បរទេស គឺ ផ្នែកលើ ចាគ ប័ត្រ[4] របស់ ប្រជាពលរដ្ឋខ្មែរ នាំគ្នា រស់នៅ នៅក្នុង សន្តិភាព ភ័យរន្ធត់ បង្កើតឡើង ដោយ រដ្ឋ ភេរវកម្ម។ របប ក្រុងភ្នំពេញ តែងតែ យក ស្រុកខ្មែរ ទៅ ប្រៀបធៀប ជាមួយនឹង ប្រទេស ទាំងឡាយ ដែល កំពុង មាន សង្គ្រាម ស៊ីវិល រួច ឃោសនា អរ គុណ សន្តិភាព ថា ជា ស្នាដៃល្អ របស់ ខ្លួន សំរាប់ ប្រជាពលរដ្ឋ ខ្មែរ។ តែ របប នេះ ប្រើ អំណាច នៃ អាវុធ ជំនួស ច្បាប់ សំរាប់

[3] នយ:ជន : អ្នកនយោបាយ។
[4] ចាគប័ត្រ: ការលះបង់ សិទ្ធ អោយ អ្នកណាម្នាក់, ការអត់ធ្មត់ទ្រាំទ្រ (résignation)។

ការពារ សន្តិភាព តែ មាន កង ប្រដាប់ អាវុធ ត្រៀមខ្លួន ធ្វើ សម្បហារ ប្រឆាំងនឹង ប្រជាពលរដ្ឋខ្មែរ និង ធ្វើ សម្ភាក ហិង្សា ទៅលើ ពួក ប្រឆាំងនឹង ខ្លួន ដែល គេ ប្រើ សន្តិវិធី។ អំពើ ទាំង នោះ ជា រូបភាព នៃ សង្គ្រាម មួយ មាន ឈ្មោះ ថា « អំណាច ផ្តាច់ការ ឬ រដ្ឋ ភេរវកម្ម »។

និយាយ អំពី អនាគត នៃ ការតស៊ូ នៅ ស្រុកខ្មែរ វា មិនមែន និយាយ អំពី វិទ្យាសាស្ត្រ-ប្រឌិត[5] ឬ រឿង លេងៗ នោះទ្បើយ ព្រោះ ការតស៊ូ ដើម្បី លទ្ធិប្រជាធិបតេយ្យ វា ជា ការពិត សំរាប់ ប្រជាពលរដ្ឋខ្មែរ ទោះបី គាត់ ចង់ ធ្វើ ឬ អត់ ព្រោះ ពលរដ្ឋខ្មែរ ម្នាក់ៗ បាន ធ្វើ រួចហើយ តាម សន្តិវិធី រហូត មាន ជ័យជំនះ នៅពេល បោះឆ្នោត សកល នៅ ឆ្នាំ ២០១៣ ដោយ ប្រើ អំណាច ឆន្ទានុសិទ្ធ[6] របស់ ខ្លួន បោះឆ្នោត ប្តូរ គណបក្ស ដឹកនាំ។ តែ ក ង្វះ នៅពេល នោះ ដើម្បី ធ្វើ១បាន សម្រេច នៃ ជ័យជំនះ នោះ គឺ កម្រាញ[7] រួម នៃ ពលរដ្ឋខ្មែរ និង សេចក្ដីប្ដេជ្ញា ចិត្ត នៃ ពួក មេដឹកនាំ គណបក្ស សង្គ្រោះជាតិ នៅ ចំពោះមុខ អំណាច ផ្តាច់ការ។ ប៉ុន្តែ ជ័យជំនះ មិនទាន់ចប់ នេះ ក៏ បង្ហាញ ដែរ នូវ ភាពផុយជ្ជួស នៃ របប ក្រុងភ្នំពេញ នៅ ចំពោះ លទ្ធិប្រជាធិប តេយ្យ សេរី ដែល នាំ អោយ របប នេះ ទុក លទ្ធិ នេះ ជា សត្រូវ

[5] វិទ្យាសាស្ត្រ-ប្រឌិត : science -fiction.
[6] ឆន្ទាសទ្ធិ : pouvoir discrétionnaire.
[7] កម្រាញ : ការក្រាញ, résistance.

នឹង ខ្លួន តែម្តង គឺថា រំលាយ គណបក្សប្រឆាំង ជា វិជយិន[8] ក្នុង ការប្រយុទ្ធ តាម ប្រការ នៃ លទ្ធិប្រជាធិបតេយ្យ សេរី និង ចោទប្រកាន់ មេ គណបក្ស ជា អ្នកឈ្នះ ថា ជា ជនក្បត់ជាតិ ហើយ ធ្វើការបោះឆ្នោត ក្លែងក្លាយ ដើម្បី បំភាន់ មតិជាតិ និង អន្តរជាតិ ដោយ ប្តូរ របប នយោបាយ ពី ពហុបក្ស ទៅជា ឯក បក្ស ដែល ផ្ទុយនឹង ខ្លឹមសារ នៃ រដ្ឋធម្មនុញ្ញជាតិ។ ជម្រើស នេះ រុញ របប ក្រុងភ្នំពេញ អោយធ្លាក់ ទៅក្នុង ស្នាមភ្លោះ ដ៏ ជ្រៅ នៃ អំពើ ហិង្សា ជា ចេតនា ដើម្បី រក្សា អំណាច ផ្តាច់ការ។ សួរ ថា តើ របប នេះ នឹងអាច រារ ឡើង ពី ស្នាមភ្លោះ អកុសល នោះ មក រក ពន្លឺ ស៊ីវិល័យ បានដែរ ឬទេ ?

យើង យើញ ថា នៅក្នុង បរិបទ នយោបាយ នៅ ស្រុកខ្មែរ សព្វ ថ្ងៃ ទាំងខាង គណបក្ស ប្រឆាំង ខាង របប ក្រុងភ្នំពេញ និង ខាង ប្រជាពលរដ្ឋ សុទ្ធ តែ មាន ចំណុច ខ្សោយ របស់ ខ្លួន រៀ ងៗ ខ្លួន ដែល មិនអាច បក់ បញ្ចេញ ពួរ:សង្ឃរា នយោបាយ អាប់អួ ដែល ធ្វើអោយ ស្រុកខ្មែរ ស្ថិត នៅក្នុង ភាពងងឹត ហើយ ទទួល ទណ្ឌកម្ម ជា អាទិ ពី សំណាក់ សហគមន៍ អ៊ីរ៉ុប ដែល នាំអោយ ប្រជាជាតិខ្មែរ អាប់ឱន កិត្តិយស លើ ឆាក អន្តរជាតិ ព្រោះ គេ មើល យើញ ថា ស្រុកខ្មែរ ស្ថិត នៅ ជា ជ ង្រុក នៃ អកុសល ទោះបី ខ្លួន បានទទួល ជំនួយ បរទេស គ្រប់ វិស័យ ដូចយ៉ាង វិស័យ នយោបាយ គឺ កិច្ចព្រមព្រៀង សន្តិភាព

[8] វិជយិន : អ្នកមានជ័យ, ដែលមានជ័យ។

២១ តុលា ឆ្នាំ ១៩៩១, វិស័យ សេដ្ឋកិច្ច គឺ EBA, វិស័យ យុត្តិធម៌ គឺ តុលាការ កាត់ក្តី មេ ដឹកនាំ មួយចំនួន នៃ របប «ខ្មែរ ក្រហម», វិស័យ សង្គម គឺ មាន អង្គការ ក្រៅ រដ្ឋាភិបាល ធ្វើ សកម្មភាព ដើម្បី លើកស្ទួយ តម្លៃ សង្គមខ្មែរ។ល។ អកុសល នោះ បង្ហាញ នូវ អសមត្ថភាព នៃ ក្រប់ កម្លាំងជាតិ មាន ប្រជាពលរដ្ឋ, អង្គការ នយោបាយ, អង្គការ សង្គម ស៊ីវិល នឹង អាច យកឈ្នះ រួមគ្នា លើ អកុសល ដែល កំពុង វាយប្រហារ លើ ប្រជាជាតិខ្មែរ នោះបាន។ ដូច្នេះ អនាគត នៃ ការតស៊ូ របស់ ប្រជាជាតិខ្មែរ គឺ ការភ្ជាល់ យកឈ្នះ លើ ជម្លោះ នយោបាយ ឥតផល, អំពើ អសីលធម៌, អំពើ អយុត្តិធម៌ ដែល មាន នៅ ស្រុកខ្មែរ សព្វថ្ងៃ។ ពាក្យ អរគុណ សន្តិភាព ដែល របប ក្រុង ភ្នំពេញ លើកឡើង មក ធ្វើ ជា តម្លៃដាច់ខាត របស់ ខ្លួន បើ គ្មាន តម្លៃ នៃ សីលធម៌, យុត្តិធម៌ និង ប្រជាធិបតេយ្យ វា គ្រាន់ តែ ជា ពាក្យ ប្រហោង តែ ប៉ុណ្ណោះ។ គណបក្ស ប្រឆាំង មាន តម្លៃ ជា អ្នកប្រឆាំង មាន ប្រយោជន៍ គឺ ការប្រឆាំង ដើម្បី លើកស្ទួយ លទ្ធិប្រជាធិបតេយ្យ មិនមែន ស្វែង រក ផល ប្រយោជន៍ អោយ បក្ស ឬ បុគ្គល ដោយ ធ្វើ សិទ្ធិលភាព ជាមួយ ពួក ជនផ្តាច់ការ ដើម្បី ចែក ប្រយោជន៍ គ្នា នោះឡើយ។ រីឯ ពលរដ្ឋខ្មែរ ម្នាក់ៗ ដែល ទុក ខ្លួន ជា ជនរងគ្រោះនឹង អយុត្តិធ ម៌ ត្រូវ ប្រមូលផ្តុំគ្នា ជា កម្លាំង តស៊ូរួម ដើម្បី ពោលអះអាង ជា ឆន្ទៈរួម និង រិះមាន នៅចំពោះមុខ អំណាច ជិះជាន់។ គុណ ភាព នៃ បុគ្គលម្នាក់ៗ នៅក្នុង ការតស៊ូ វា មិនគ្រប់គ្រាន់ សំ

រាប់ ប្រឆាំងនឹង អំណាច ហិង្សា នោះឡើយ, ដូច្នេះ ត្រូវ ផ្តុំ ចង កម្លាំង បុគ្គល ឱ្យ ក្លាយ ជា កម្លាំង សមូហជន ទើប វា អាច ជា ចលករ សំរាប់ យក ឈ្នះ លើ របប ផ្តាច់ការ បាន។ ក្រប់ តម្លៃ ជា រិដ្ឋមាន ដែល បានលើក មក និយាយ ខាងលើ នោះ គឺ ជា អនាគត នៃ ការតស៊ូ ដើម្បី សេចក្តី រុករឿង នៃ ប្រជាជាតិខ្មែរ នោះឯង។